ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

លេខ : 18 ក.ជ.ក.ក

ភ្នំពេញ, ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០០

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតអនុគណៈកម្មការពលកម្មកុមារ និងទំរង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀត មកលើកុមារ

## ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៥៦ អនក្របក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- បានឃើញអនុស្សរណៈនៃការយោគយល់រវាង ក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន និងអង្គការពលកម្មអន្តរជាតិ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៩៧

## សំរេច

<u>ប្រការ ១</u> ៖ បង្កើតអនុគណៈកម្មការពលកម្មកុមារ និងទំរង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្នុងគោលបំណងធានាកិច្ចអនុវត្តន៍ការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើគោលនយោបាយទាំងឡាយ និងកម្មវិធីដែលទាក់ទងទៅនឹងពលកម្មកុមារ និងទំរង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារ ។

<u>ប្រការ ២</u> ៖ អនុគណៈកម្មការនេះនឹងបំពេញមុខងារជាក្រុមការងារជាតិពលកម្មកុមារ និងទំរង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារ នៅក្នុងប្រទេសកម្ពុជា ។

<u>ប្រការ ៣</u> ៖ អនុគណៈកម្មការពលកម្មកុមារ និងទំរង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារ មានភារៈកិច្ចដូចតទៅ ៖

- ធ្វើការពិគ្រោះយោបល់លើប្រភេទ និងទំហំ នៃសកម្មភាពដែលត្រូវអនុវត្តក្នុងគំរោងកម្មវិធីជាតិពលកម្មកុមារ និងទំរង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារ ដោយដោយផ្អែកលើគោលនយោបាយ និងបទប្បញ្ញត្តិជាតិ ដែលពាក់ព័ន្ធ ។
- ជ្រើសរើសកម្មវិធី សកម្មភាពដែលស្នើឡើងដោយបណ្តាស្ថាប័នរដ្ឋាភិបាល អង្គការសមាគមក្រៅរដ្ឋាភិបាលក្នុងស្រុកដើម្បីស្វែងរកការជួយឧបត្ថម្ភគាំទ្រ ពីអង្គការ ភ្នាក់ងារ ឬឯកត្តជនផ្តល់ជំនួយនានា ក្នុងក្របខ័ណ្ឌនៃកម្មវិធីជាតិស្តីពី ការលុបបំបាត់ពលកម្មកុមារ និងទំរង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារ។
- ផ្តល់នូវពត៌មាន និងយុត្តិកម្ម ស្តីពីកម្មវិធី និងថវិកា តាមកាលកំណត់ច្បាស់លាស់ និងតាមការស្នើសុំរបស់អង្គការ ភ្នាក់ងារ ឬឯកត្តជនផ្តល់ជំនួយនានា ។
- ពិនិត្យឡើងវិញនូវរាល់កម្មវិធីដែលកំពុងដំណើរការក្នុងក្របខ័ណ្ឌនៃកម្មវិធីជាតិ ស្តីពីការលុបបំបាត់ពលកម្មកុមារ និងទំរង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារក្នុងបរិបទកម្មវិធីជាតិទាំងមូល ។
- ធ្វើការពិភាក្សា និងសម្របសម្រួលរាល់សកម្មភាពទាំងឡាយ ដែលពាក់ព័ន្ធនឹងបញ្ហាពលកម្មកុមារ នៅក្នុងប្រទេសកម្ពុជា ដោយសហការជាមួយអ្នកដើរតួនាទីសំខាន់ៗក្នុងបញ្ហាពលកម្មកុមារ ។
- រាយការណ៍ជាប្រចាំជូនទៅក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារស្តីពីគោលនយោបាយកម្មវិធី និងពត៌មានដែលទាក់ទងទៅនឹងបញ្ហាពលកម្មកុមារ ។

<u>ប្រការ ៤</u> ៖ សមាសភាពនៃអនុគណៈកម្មការពលកម្មកុមារ និងទំរង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារ រួមមាន ៖

១- ឯកឧត្តម រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងជាប្រធានក្រុមប្រឹក្សាជាតិ កម្ពុជាដើម្បីកុមារ ជាប្រធាន

២- ឯកឧត្តម វង្ស សូត្រ អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា	ជាអនុប្រធាន

៣- ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាល
វិជ្ជាជីវៈ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា	ជាអនុប្រធាន

៤- តំណាងក្រសួងមហាផ្ទៃ	ជាសមាជិក

៥- តំណាងក្រសួងអប់រំ យុវជន និងកីឡា	ជាសមាជិក

៦- តំណាងក្រសួងសុខាភិបាល	ជាសមាជិក

៧- តំណាងក្រសួងកិច្ចការនារី និងអតីតយុទ្ធជន	ជាសមាជិក

៨- តំណាងក្រសួងយុត្តិធម៌	ជាសមាជិក

៩- តំណាងក្រសួងអភិវឌ្ឍន៍ជនបទ	ជាសមាជិក

១០- តំណាងក្រសួងទេសចរណ៍	ជាសមាជិក

១១- តំណាងក្រសួងពត៌មាន	ជាសមាជិក

១២- តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	ជាសមាជិក

១៣- តំណាងក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ	ជាសមាជិក

១៤- ឯកឧត្តមទីប្រឹក្សាអមក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាល
វិជ្ជាជីវៈ និងយុវនីតិសម្បទា ទទួលបន្ទុកវិស័យការងារ	ជាសមាជិក

១៥- តំណាងនាយកដ្ឋានសុខុមាលភាពកុមារ នៃក្រសួងសង្គមកិច្ច
ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា	ជាសមាជិក

១៦- តំណាងសមាគមនិយោជក	ជាសមាជិក

១៧- តំណាងអង្គការសហជីព	ជាសមាជិក

១៨- តំណាង៣រូប នៃអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក	ជាសមាជិក

ប្រការ ៥ : តំណាងភ្នាក់ងារអង្គការសហប្រជាជាតិ និងអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិនិងបណ្តាឯកត្តជនដែលចាប់អារម្មណ៍ អាចចូលជាសមាជិកសង្កេតការណ៍ ហើយអាចចូលរួមប្រជុំតាមការអញ្ជើញរបស់អនុគណៈកម្មការ ។

ប្រការ ៦ : អនុគណៈកម្មការពលកម្មកុមារ និងទំរង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារ មានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយដែលមានឈ្មោះថាផ្នែកពលកម្មកុមារ ចំណុះអោយអគ្គនាយកដ្ឋានការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

ប្រការ ៧ : តួនាទី និងភារៈកិច្ចរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍ នឹងត្រូវកំណត់ដោយអនុគណៈកម្មការពលកម្មកុមារ និងទំរង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារ ។

ប្រការ ៨ : អនុគណៈកម្មការស្តីអំពីពលកម្មកុមារមានថវិកាមួយដោយឡែក ដែលបានមកពីការជួយឧបត្ថម្ភគាំទ្រដោយអង្គការ ភ្នាក់ងារឬឯកត្តជនផ្តល់ជំនួយនានា ហើយដែលបច្ចុប្បន្ននេះ ជាឧបសម្ព័ន្ធថវិការបស់ផ្នែកពលកម្មកុមារ ដែលឧបត្ថម្ភគាំទ្រដោយអង្គការពលកម្មអន្តរជាតិ កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ ។

ប្រការ ៩ : អនុគណៈកម្មការពលកម្មកុមារ និងទំរង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ។

ប្រការ ១០ : អនុគណៈកម្មការពលកម្មកុមារ និងទំរង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារ មានបទបញ្ជាផ្ទៃក្នុងដោយឡែករបស់ខ្លួន ។

ប្រការ ១១ : រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសំរេចនេះត្រូវចាត់ជានិរាករណ៍ ។

ប្រការ ១២ : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។ ៚

ជ. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

ប្រធាន

អ៊ិត សំហេង

ចំលងជូន :

-ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីជូនជ្រាបជាពត៌មាន"

-ដូចប្រការ ៤ "ដើម្បីអនុវត្ត"

-ឯកសារ- កាលប្បវត្តិ

-រាជកិច្ច